# គម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទជំហាន ២

## សេចក្តីសង្ខេបអំពីក្របខ័ណ្ឌផែនការជនជាតិដើមភាគតិច

ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) បានធ្វើបច្ចុប្បន្នភាពក្របខណ្ឌផែនការជនជាតិដើមភាគតិច (IPPF) សម្រាប់ដំណាក់កាលទី២ នៃគម្រោងពង្រឹងសមត្ថភាពផលិតភាពជនបទ (NRRPCP-II) ដែលជាគំនិតផ្តួចផ្តើមដែលទទួលបានហិរញ្ញប្បទានពី ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB) ដើម្បីពង្រឹងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ បង្កើនឱកាសសេដ្ឋកិច្ច និងបង្កើនលទ្ធភាពទទួលបានសេវាសំខាន់ៗនៅទូទាំងខេត្តចំនួន១០ ។ ក្របខណ្ឌដែលបានធ្វើបច្ចុប្បន្នភាពនេះនឹងធានាថា សិទ្ធិ អត្តសញ្ញាណ និងជីវភាពរស់នៅរបស់ ជនជាតិដើមភាគតិច (IPs) ត្រូវបានគោរពយ៉ាងពេញលេញដោយគម្រោង ហើយសហគមន៍ជនជាតិដើមភាគតិចនឹងទទួលបានផលប្រយោជន៍ស្មើៗគ្នានៅក្នុងការអភិវឌ្ឍន៍ជនបទ ។

គម្រោង NRRPCP-II មានគោលបំណងស្តារឡើងវិញនូវផ្លូវជនបទប្រមាណ ៤១២ គីឡូម៉ែត្រ នៅក្នុងខេត្តកំពង់ឆ្នាំង ត្បូងឃ្មុំ ព្រៃវែង បាត់ដំបង កំពង់ធំ តាកែវ កណ្តាល ស្វាយរៀង កំពត និងកែប ។ ផ្លូវដែលនឹងត្រូវបានស្តារឡើងវិញទាំងនេះត្រូវបានរំពឹងថា នឹងធ្វើឲ្យប្រសើរឡើងនូវការធ្វើដំណើរពេញមួយឆ្នាំសម្រាប់ប្រជាជននៅទីជនបទ ។ ហេដ្ឋារចនាសម្ព័ន្ធដែលនឹងកែលម្អនេះ នឹងជួយដល់ការធ្វើដំណើរ ការដឹកជញ្ជូនផលិតផលកសិកម្ម និងការតភ្ជាប់ទៅកាន់មណ្ឌលសុខភាព ទីផ្សារ និងសាលារៀន ។ វាត្រូវបានព្យាករណ៍ថាមានប្រជាជននៅជនបទប្រមាណ ១,០០០,០០០ នាក់ នឹងទទួលបានអត្ថប្រយោជន៍ផ្ទាល់ពីគម្រោង

រួមទាំងក្រុមងាយរងគ្រោះ ដូចជា ស្ត្រី កុមារ យុវជនគ្មានការងារធ្វើ ជនចាស់ជរា ជនមានពិការភាព ពលករចំណាកស្រុកដែលត្រឡប់មកវិញ និងសហគមន៍ជនជាតិដើមភាគតិច ។ លើសពីនេះ គម្រោងនេះត្រូវបានរំពឹងថានឹងបង្កើតការងាររយៈពេលខ្លីប្រមាណ ៥០,០០០ កន្លែង និងគាំទ្រដល់ការចូលរួមរបស់ក្រុមហ៊ុនម៉ៅការសាងសង់ក្នុងស្រុក ដើម្បីពង្រឹងសមត្ថភាពក្នុងស្រុក ។

ក្របខណ្ឌ IPPF ដែលបានធ្វើបច្ចុប្បន្នភាពនេះ គឺស្របតាម ក្របខណ្ឌបរិស្ថាន និងសង្គម (ESF) ឆ្នាំ ២០២៤ របស់ AIIB ជាពិសេស ស្តង់ដារបរិស្ថាន និងសង្គមទី៣ (ESS3) ស្តីពីជនជាតិដើមភាគតិច។ វាក៏ឆ្លុះបញ្ចាំងពីក្របខណ្ឌច្បាប់ និងគោលនយោបាយរបស់ រាជរដ្ឋាភិបាលកម្ពុជា (RGC) ផងដែរ ដោយធានានូវការអនុលោមតាមតម្រូវការជាតិសម្រាប់កិច្ចគាំពារជនជាតិភាគតិច ការមិនរើសអើង និងការអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្ន។ ក្របខណ្ឌនេះកំណត់និយមន័យនូវដំណើរការកិច្ចគាំពារយ៉ាងច្បាស់លាស់ដែលត្រូវអនុវត្តចំពោះអនុគម្រោងទាំងអស់ ដើម្បីកំណត់អត្តសញ្ញាណវត្តមានរបស់ ជនជាតិដើមភាគតិច វាយតម្លៃផលប៉ះពាល់ដែលអាចកើតមានដោយគម្រោង និងធានាការចូលរួមប្រកបដោយអត្ថន័យ និងការគោរពវប្បធម៌ប្រពៃណីយរបស់ពួកគេក្នុងការរៀបចំផែនការ និងការអនុវត្តគម្រោង។

IPPF បានកំណត់គោលការណ៍ស្នូលចំនួនបីនោះគឺៈ ទីមួយ គម្រោងនឹងធានាថា IPs នឹងត្រូវបានពិគ្រោះយោបល់ និងអាចចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចលើប៉ះពាល់ដល់ដីធ្លី ជីវភាពរស់នៅ និងបេតិកភណ្ឌវប្បធម៌របស់ពួកគេប្រសិនបើមាន។ ទីពីរ គម្រោងនឹងផ្តល់អត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចសមស្របតាមវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច តាមវិធានការដាក់ជនជាតិដើមភាគតិចនៅក្នុងក្រុមគោលដៅទទួលផលពីគម្រោង។ ទីបី គម្រោងធានាថាផលប៉ះពាល់អវិជ្ជមានដែលអាចកើតចេញពីការសាងសង់ ការប្រើប្រាស់ដីធ្លី ឬធនធានធម្មជាតិ—ត្រូវបានជៀសវាង កាត់បន្ថយ ឬដោះស្រាយតាមរយៈការរៀបចំផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច (IPPs) និងការចូលរួមរបស់សហគមន៍ជាបន្តបន្ទាប់។

ក្របខណ្ឌនេះត្រូវបានបង្កើតឡើងដោយមានរចនាសម្ព័ន្ធ និងយន្តការ ដើម្បីកំណត់វត្តមានរបស់ជនជាតិដើមភាគតិចនៅតំបន់របស់អនុគម្រោង ។ នីតិវិធីនៃការត្រួតពិនិត្យ និង វាយតម្លៃផលប៉ះពាល់ជនជាតិដើមភាគតិច ដែលនឹងត្រូវអនុវត្តន៍ចាប់តាំងពីដំណាក់កាលដំបូងនៃការតាក់តែងគម្រោង ដើម្បីកំណត់ថាតើសហគមន៍ជនជាតិដើមភាគតិចរស់នៅ ប្រើប្រាស់ ឬមានវប្បធម៌ ឬអាស្រ័យផលជាមួយតំបន់គម្រោង

ដែរឬទេ ។ ប្រសិនបើការត្រួតពិនិត្យវាយតម្លៃបញ្ជាក់ពីវត្តមានរបស់ជនជាតិដើមភាគតិចនោះ ការវាយតម្លៃផលប៉ះពាល់សង្គម(SIA) នឹងត្រូវធ្វើឡើង ដើម្បីស្វែងយល់ពីលក្ខណៈរបសសហាគមន៍ រចនាសម្ព័ន្ធសង្គម វប្បធម៌ របៀបនៃការប្រើប្រាស់ដីធ្លី ធនធាន និងហានិភ័យ ឬឱកាសដែលអាចកើតមាន ។ ដោយផ្អែកលើលទ្ធផលដែលទទួលបានពីការត្រួតពិនិត្យវាយតម្លៃនេះ IPPs នឹងត្រូវរៀបចំឡើង ដើម្បីចងក្រងឯកសារអាទិភាពរបស់សហាគមន៍ កំណត់អត្ថប្រយោជន៍ និងបញ្ជាក់ពីវិធានការនៃការដោះស្រាយផលប៉ះពាល់អវិជ្ជមាន ។ ក្នុងករណីដែលសកម្មភាពគម្រោងអាចប៉ះពាល់ដល់ដីធ្លីរ ប្រពៃណី ធនធានធម្មជាតិក្រោមការកាន់កាប់ដោយសមូហភាព ឬប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌ គម្រោងត្រូវតែធ្វើ Free, Prior, and Informed Consent (FPIC) ពីសហាគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ ។ IPPF ផ្តល់ការណែនាំ FPIC យ៉ាងច្បាស់លាស់ស្របតាម AIIB ESF 2024។ FPIC ត្រូវបានកំណត់សម្រាប់សកម្មភាពដែលអាច៖ (i) មានផលប៉ះពាល់លើដីធ្លី ឬធនធានធម្មជាតិក្រោមកម្មសិទ្ធិសមូហភាព; (ii) បណ្តាលឱ្យមានការផ្លាស់ប្តូរទីលំនៅ ការរឹតត្បិតលើការប្រើប្រាស់ដីធ្លី ឬការរិតត្បិតលើការទទួលបានធនធានធម្មជាតិ ឬ (iii) ប៉ះពាល់យ៉ាងខ្លាំងដល់បេតិកភណ្ឌវប្បធម៌ ទីតាំងសក្ការៈបូជា ឬធនធានដែលគ្រប់គ្រងដោយសមូហភាព ។ ដំណើរការ FPIC ត្រូវតែផ្អែកលើការចរចាដោយសុច្ឆរិត តម្លាភាព ការទំនាក់ទំនងសមស្របតាមវប្បធម៌ និងឯកសារគាំទ្ររបស់សហាគមន៍ ។

ក្របខណ្ឌនេះក៏បានបញ្ជាក់ច្បាស់ពីតួនាទី និងទំនួលខុសត្រូវរបស់ស្ថាប័នផងដែរ ដោយតម្រូវឱ្យ អង្គភាពគ្រប់គ្រងគម្រោង (PMU) របស់ក្រសួងអភិវឌ្ឍន៍ជនបទ អង្គភាពអនុវត្តគម្រោងថ្នាក់ខេត្ត (PIUs) និង គណៈកម្មាធិការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត (PRSCs) ត្រូវសម្របសម្រួលយ៉ាងជិតស្និទ្ធក្នុងការអនុវត្តសកម្មភាពដែលពាក់ព័ន្ធនឹង IPs ។ ការពិគ្រោះយោបល់ និងការទំនាក់ទំនងជាមួយ ជនជាតិដើមភាគតិចនឹងបន្តជាប្រចាំពេញមួយវដ្តនៃគម្រោង ។ ក្របខណ្ឌនេះសង្កត់ធ្ងន់លើការប្រើប្រាស់ភាសាជនជាតិដើម ការទំនាក់ទំនងផ្ទាល់មាត់ ការបង្ហាញរូបភាព និងតំណាងសហាគមន៍ដែលគួរឱ្យទុកចិត្ត ដើម្បីធានាបាននូវភាពងាយស្រួល ។ ដំណើរការពិគ្រោះយោបល់ត្រូវតែប្រកាន់ខ្ជាប់នូវភាពរសើបនៃយេនឌ័រ និងរួមបញ្ចូលក្រុមងាយរងគ្រោះ រួមមាន ស្ត្រី ជនចាស់ជរា យុវជន និងគ្រួសារដែលមានប្រាក់ចំណូលទាប ។ ការប្រជុំដាច់ដោយឡែកអាចនឹងត្រូវធ្វើឡើង ដើម្បីធានាថា ក្រុមងាយរងគ្រោះមិនត្រូវបានរើសអើងនិង ងាយស្រួលក្នុងការបញ្ចេញមតិយោបល់។ លទ្ធផលនៃការពិគ្រោះយោបល់នឹងត្រូវបានចងក្រងជាឯកសារ និងបញ្ចូលទៅក្នុងការតាក់តែងគម្រោង ដែលធានាថា យោបល់របស់ជនជាតិដើមភាគតិចនឹងត្រូវបានទទួល

យកក្នុងការអនុវត្តគម្រោង ។ យន្តការដោះស្រាយបណ្តឹងតវ៉ា (GRM) ដែលមានតម្លាភាពនឹងត្រូវបានបង្កើតឡើងនៅក្នុងខេត្តរបស់គម្រោងនីមួយៗ ដើម្បីធានាថា ជនជាតិដើមភាគតិចនិងបុគ្គលដែលរងផលប៉ះពាល់ផ្សេងទៀតអាចដាក់ពាក្យបណ្តឹងនៅដំណាក់កាលណាមួយនៃការអនុវត្ត ។ GRM ត្រូវបានរៀបចំឡើងឱ្យសមស្របតាមវប្បធម៌ យេនឌ័រ តម្លាភាព និងងាយស្រួលប្រើប្រាស់ ។

ប្រព័ន្ធតាមដាន និងវាយតម្លៃត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌ ដើម្បីធានាថា ការប្តេជ្ញាចិត្តចំពោះជនជាតិដើមភាគតិចនឹងត្រូវបានរក្សាយ៉ាងពេញលេញក្នុងគម្រោង ។ MRD និង PMU នឹងត្រួតពិនិត្យការអនុវត្ត IPPs និងតម្រូវការនានាក្រោមកិច្ចគាំពារសុវត្ថិភាព ។ របាយការណ៍ត្រួតពិនិត្យនឹងតាមដានលទ្ធផលនៃការពិគ្រោះយោបល់ ការចូលរួមរបស់សហគមន៍ ការដោះស្រាយផលប៉ះពាល់ ការចែករំលែកផលប្រយោជន៍ និងការដោះស្រាយបណ្តឹងតវ៉ា ។ ការពិនិត្យឡើងវិញពាក់កណ្តាលឆមាស នឹងវាយតម្លៃការអនុវត្ត IPP នឹងកំណត់បញ្ហាប្រឈមនៃការអនុវត្ត និងសកម្មភាពដែលត្រូវកែតម្រូវ ។ ភាគីទីបីនៃការវាយតម្លៃលើការអនុវត្ត IPP ក៏នឹងត្រូវចូលរួមជារៀងរាល់ឆ្នាំផងដែរ ដើម្បីផ្តល់ការវាយតម្លៃឯករាជ្យនៃការអនុវត្ត IPP សមស្របតាមវប្បធម៌ និងការពេញចិត្តរបស់សហគមន៍ជាទូទៅចំពោះដំណើរការ និងលទ្ធផលគម្រោង ។ IPPF សង្កត់ធ្ងន់លើទំនួលខុសត្រូវរបស់ MRD ក្នុងការបែងចែកធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការរៀបចំ និងការអនុវត្ត IPPs ។ ការចំណាយដែលទាក់ទងនឹងវិធានការទប់ស្កាត់ ការបង្កើនអត្ថប្រយោជន៍ ការពិគ្រោះយោបល់ជាមួយសហគមន៍ និងសកម្មភាពលើកកម្ពស់ការយល់ដឹង នឹងត្រូវបានបញ្ចូលទៅក្នុងគម្រោងថវិកាចំណាយរបស់គម្រោង ។ PMU ទទួលខុសត្រូវក្នុងការផ្ទេរមូលនិធិទៅ PIUs ដើម្បីធានាការអនុវត្តទាន់ពេលវេលា ហើយសកម្មភាពកសាងសមត្ថភាពនឹងត្រូវបានរៀបចំ ដើម្បីពង្រឹងសមត្ថភាពស្ថាប័នមូលដ្ឋានក្នុងការអនុវត្តក្របខណ្ឌប្រកបដោយប្រសិទ្ធភាព សរុបមក ក្របខណ្ឌផែនការជនជាតិដើមភាគតិចដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់ NRRPCP-II តំណាងឱ្យការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ចំពោះការអភិវឌ្ឍន៍ជនបទប្រកបដោយបរិយាប័ន្ន ទំនួលខុសត្រូវ និងការគោរពវប្បធម៌របស់ជនជាតិដើមភាគតិច ។ ក្របខណ្ឌនេះនឹងធានាថា ជនជាតិដើមភាគតិចដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងទេសភាពវប្បធម៌ និងបរិស្ថានរបស់កម្ពុជា ជាអ្នកចូលរួមយ៉ាងសកម្ម និងជាអ្នកទទួលបានផលពីការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ។ តាមរយៈការរួមបញ្ចូលការគាំពារ ការពិគ្រោះយោបល់ FPIC និងការធ្វើសេចក្តីសម្រេចដែលជំរុញដោយសហគមន៍ទៅក្នុងដំណាក់កាលនីមួយៗនៃការរៀបចំផែនការ និងការអនុវត្ត

គម្រោង IPPF មានគោលបំណងលើកកម្ពស់ការអភិវឌ្ឍន៍ដែលមានសមធម៌ និរន្តរភាព និងសមស្របតាមវប្បធម៌របស់ IPs ។ ក្របខណ្ឌនេះមិនត្រឹមតែគូសបញ្ជាក់អំពីគោលការណ៍គាំពារជនជាតិដើមភាគតិចតពីផលប៉ះពាល់អវិជ្ជមានប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏នឹងត្រូវដាក់បញ្ចូលអោយទទួលបានអត្ថប្រយោជន៍ពីគម្រោងក៏ដូចជាការអភិវឌ្ឍន៍របស់ជាតិផងដែរ ។